**សេចក្តីប្រកាសព័ត៌មាន**

សំរាប់ការផ្សាយបន្ទាន់

ថ្ងៃច័ន្ទ ទី ១៣ ខែមិថុនា ឆ្នាំ ២០១១

# ស-សបាសាក់ សូមបង្ហាញជូននូវពិព័រណ៍សិល្បៈក្រោមចំណងជើង *ក្នុងក្លឹប* ដោយ អ៊ុក សុជីវី




អ៊ុក សុជីវី, *ក្រុមរាំនារី*, ឆ្នាំ២០១១, គំនូរប្រេងលើក្រណាត់, ទំហំ ៦០x ៨០ សង់ទីម៉ែត្រ

**ទីក្រុងភ្នំពេញ** – ស-សបាសាក់ មានសេចក្តីសោមនស្សរីករាយ សូមបង្ហាញជូនពិព័រណ៍សិល្បៈដោយ អ៊ុក សុជីវី ក្រោមចំណងជើងថា *ក្នុងក្លឹប* ដែលជាកំរងផ្ទាំងគំនូរឆ្លុះបញ្ចាំងពីសកម្មភាពនិងម៉ូតសម្លៀកបំពាក់នៅតាមក្លឹបរាត្រីក្នុងទីក្រុងភ្នំពេញ។

សុជីវី កើតនៅក្នុងទីក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៨៤។ នាង គឺជាប្រជាជនម្នាក់ ក្នុងចំណោមប្រជាជនចំនួន ៧០% នៅក្នុងប្រទេសកម្ពុជា ដែលមានអាយុក្រោម ៣០ ឆ្នាំ។ នាងបានធំដឹងក្តីក្នុងអំឡុងពេលដែលកម្ពុជាទើបចាប់ផ្តើមដំណើរការអភិវឌ្ឍន៍ប្រទេស និងទីក្រុង។ នាងត្រូវបានគេស្គាល់ តាមរយៈស្នាដៃគំនូររបស់នាង ដែលបង្ហាញពីយុវជនយុវនារីខ្មែរមួយក្រុម ដែលគេនិយមហៅថា ហ្រ្វែស្ស៊ី។ ដោយត្រូវបានគេចាត់ទុកថាជាស្ទីល និងអត្តសញ្ញាណមួយផុសចេញពីតម្រូវការនៃកម្មវិធីប្រកួតប្រជែងទេពកោសល្យនានាដែលផ្សាយតាមកញ្ចក់ទូរទស្សន៍ជាញឹកញាប់ ក្រុមហ្រ្វែស្ស៊ីបាននាំចូលមកក្នុងប្រទេសកម្ពុជានូវនិន្នាការនៃសម្លស្ស និងម៉ូតអន្តរជាតិពេញនិយមពីបណ្តាប្រទេសជិតខាងក្នុងអាស៊ី។

គំនូរ *ក្នុងក្លឹប* ទាំង ១១ ផ្ទាំង ត្រូវបានពិពណ៌នាដោយចំណងជើងច្បាស់ៗ និងបង្ហាញឱ្យឃើញពីតួអង្គ និងបែបផែននៃវប្បធម៌ក្នុងក្លឹបរបស់ប្រទេសកម្ពុជា។ ក្លឹបជាច្រើន ក៏ជាបារ ឌីស្កូ កន្លែងដើរបង្ហាញម៉ូត និងកន្លែងសម្រាប់កម្មវិធីសម្តែងកម្សាន្តផងដែរ ដូច្នេះម៉ូតនិងស្ទីលមានសារៈសំខាន់យ៉ាងខ្លាំងចំពោះជីវិតពេលរាត្រី ដែលធ្វើឱ្យអ្នកទាំងឡាយប្រែក្លាយពីអ្នកទស្សនា ទៅជាអ្នកកម្សាន្ត ឬអ្នកសម្តែង។

*ឌីជេនិងតុចាក់ឌីស* ត្រូវបានគូរបែបជា «ស្ទីលហ៊ីបហប់» ដោយសំដៅលើការវិវត្តន៍និងការស្លៀកពាក់របស់ក្រុមខ្មែរហ៊ីបហប់ ដែលទើបចាប់ផ្តើមកើតមានឡើង ដោយយកលំនាំតាមអាមេរិកាំង។ ចំណែកឯរូបគំនូរ *ក្រុមតន្ត្រី* និង*ក្រុមចម្រៀង* បង្ហាញពី «ស្ទីលតារាប្រជាប្រិយ» គឺសំដៅលើតន្ត្រីករ និងភ្ញៀវ ដែលសម្តែងផ្ទាល់នៅតាមបន្ទប់ខារ៉ាអូខេ ហើយដែលជារឿយៗពួកគេស្លៀកសម្លៀកបំពាក់លំនាំទស្សវត្សឆ្នាំ ៦០។ រូបគំនូរ *ក្រុមនារីរាំ* បង្ហាញឱ្យឃើញពីប្រភេទ «ក្លឹប» ដែលបង្កើតឡើងនៅតាមស្ថានីយទូរទស្សន៍សម្រាប់ការផ្សាយបន្តផ្ទាល់ ហើយដែលការរាំស្រុះគ្នាអាចប្រៀបប្រដូចទៅនឹងចលនាលំហាត់ប្រាណដោយយកចិត្តទុកដាក់ បើទោះបីជាមានលក្ខណៈរៀបចំបន្តិចក៏ដោយ។ រូបគំនូរ *ម៉ូតគូសង្សា* គឺជាការអធិប្បាយអំពីគូសង្សាជាច្រើនដែលនាពេលបច្ចុប្បន្ននេះនិយមស្លៀកសម្លៀកបំពាក់ម៉ូតដូចគ្នា ។

វិធីសាស្ត្រផ្ទាល់របស់សុជីវី ចំពោះបច្ចេកទេស និងតួអង្គនៅក្នុងគំនូររបស់នាង គឺជាការអនុវត្តន៍ដែលបន្សល់ទុកពីជីតារបស់នាង ឈ្មោះលោកតា ស្វាយ គេន (១៩៣៣-២០០៩) ដែលគេតែងហៅថាជា ជីតានៃសិល្បៈសហសម័យ នៅក្នុងប្រទេសកម្ពុជា។ មរតកនៃជំនាញនេះ បានឱ្យនាងបន្តនូវគោលបំណងរបស់លោកតា ស្វាយ គេន ក្នុងការរក្សាទុកនូវកំនត់ត្រានៃជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្មែរ សម្រាប់មនុស្សជំនាន់ក្រោយគ្រប់រូប។ ដោយឡែក គំនូររបស់សុជីវីមានភាពឃ្លាតឆ្ងាយពីគំនូររបស់លោកតា ស្វាយ គេន ដែលឆ្លុះបញ្ចាំងពីរឿងរ៉ាវផ្ទាល់ខ្លួន នៃបទពិសោធន៍ជីវិតដ៏ស្មុគស្មាញជាង ៦០ ឆ្នាំ របស់លោកតា។ ឥលូវនេះ ក្នុងវ័យ ២៧ ឆ្នាំ សុជីវី គូរពីជីវិតប្រចាំថ្ងៃក្នុងសម័យកាល*របស់នាង*។

តួអង្គនៅក្នុងគំនូររបស់ សុជីវី កើតចេញពីប្រភពជាច្រើនដូចជា រូបថតដែលកាត់ចេញពីទស្សនាវដ្តី, ការចុះទស្សនាផ្ទាល់ទៅកាន់ក្លឹបរាត្រីពេញនិយមនានានៅក្នុងទីក្រុងភ្នំពេញ (ស្ប៉ាក រ៉ក់ និងក្លាស៊ីក) និងការស្រមើស្រមៃរបស់នាង។ ខណៈពេលដែលវិចិត្រករល្បីៗនាពេលបច្ចុប្បន្ន គូរគំនូរទៅតាមបែបផែន ហើយបង្ហាញពីវប្បធម៌ដែលពួកគេចង់ឆ្លុះបញ្ចាំង គំនូររបស់សុជីវីគឺមានលក្ខណៈលើសពីការបង្ហាញពីឧស្សាហកម្មកម្សាន្តសប្បាយនេះទៅទៀត។ សុជីវីមិនមែនត្រឹមតែជាវិចិត្រករប៉ុណ្ណោះទេ នាងហាក់បីដូចជាអ្នកច្នៃម៉ូដផងដែរ។ នាងគូរពីឥរិយាបថរបស់តួរអង្គរួចហើយ ទើបគូរម៉ូតសក់ សម្លៀកបំពាក់ គ្រឿងលំអ និងគ្រឿងសំអិតសំអាងខ្លួនតាមក្រោយ។ ចុងក្រោយ គំនូររបស់នាងបង្ហាញពីទំនាក់ទំនងមួយនៅក្នុងការបង្ហាញពីវប្បធម៌របស់យុវជនដែលស្តែងចេញពីខ្លួនឯង នៅក្នុងអំឡុងពេលដែលប្រទេសកំពុងស្ថិតក្នុងដំណាក់កាលប្រែមុខមាត់។

**អំពីវិចិត្រករ៖**

អ៊ុក សុជីវី (កើតក្នុងឆ្នាំ ១៩៨៤) គឺជាវិចិត្រករ ដែលគេស្គាល់តាមរយៈរូបគំនូរពីយុវជនខ្មែរ ដែលមានលក្ខណៈដូចគំនូរគូរដោយក្មេង។ *ក្នុងក្លឹប* គឺជាពិព័រណ៌តែម្នាក់ឯងលើកទី ២ របស់សុជីវី បន្ទាប់ពីពិព័រណ៌ *នឹងមានបន្ត* ដែលបានតាំងនៅឯវិចិត្រសាលនៃមជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា ទីក្រុងភ្នំពេញ (២០០៩)។ ការតាំងពិព័រណ៌ជាក្រុមរួមមាន *កសិករនិងប្រែស្សី* នៅឯវិចិត្រសាល ស-ស ទីក្រុងភ្នំពេញ (២០១០) និង *តាំងពីដើមមកដល់ពេលបច្ចុប្បន្ន* នៅវិចិត្រសាល ១០ Chancery Lane Gallery ទីក្រុងហុងកុង (២០០៩)។

**អំពីស-សបាសាក់៖**

ស-សបាសាក់ គឺជាវិចិត្រសាល និងមណ្ឌលធនធានមួយ ដែលប្តេជ្ញាក្នុងការបង្កើត សម្របសម្រួល និងចែករំលែកវប្បធម៌ទស្សសិល្បៈសហសម័យនៅក្នុងនិងចេញពីប្រទេសកម្ពុជា។

**ព័ត៌មានលំអិតអំពីពិព័រណ៍៖**

ពិព័រណ៍៖ *ក្នុងក្លឹប* ដោយ អ៊ុក សុជីវី
បើកសម្ពោធ៖ ថ្ងៃ ព្រហស្បត្តិ៍ ទី ១៦ មិថុនា ម៉ោង ៦:០០ - ៨:០០ យប់
កាលបរិច្ឆេទ៖ ១៦ មិថុនា - ១០ កក្កដា ២០១១
ម៉ោងទស្សនា៖ ថ្ងៃព្រហស្បត្តិ៍ និងសុក្រ ម៉ោង ២-៦ ល្ងាច ថ្ងៃសៅរ៍ និងអាទិត្យ ម៉ោង ១០ ព្រឹក - ៦ ល្ងាច
ទីតាំង៖ ស-សបាសាក់ នៅផ្ទះលេខ ១៨ ជាន់ទី២ មហាវិថីសុធារស ភ្នំពេញ
គេហទំព័រ៖ www.sasabassac.com

**ទំនាក់ទំនង៖**

អេរីន ឃ្លីសុន
សហស្ថាបនិក / អ្នករៀបចំពិព័រណ៍សិល្បៈ / នាយក
ទូរស័ព្ទ +៨៥៥ (០)១២ ៥០៧ ៩១៧
អ៊ីមែល erin@sasabassac.com